អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងចេញសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/២។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាចោទប្រកាន់បញ្ជូន អោ អាន ទៅជំនុំជម្រះ ហើយនៅថ្ងៃដដែលនោះដែរ សហចៅក្រមស៊ើបអង្កេតជាតិបានលើកលែងបទចោទទាំងអស់ប្រឆាំងនឹងរូបគាត់។

អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាជាតិ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ បណ្តឹងឧទ្ធរណ៍ដាក់ដោយសហមេធាវីរបស់ជនត្រូវចោទ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ជនត្រូវចោទ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតជាតិ។

នៅថ្ងៃទី១៩, ២០ និង ២១ ខែមិថុនា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានបើកសវនាការក្នុងសំណុំរឿង០០៤/២ ដើម្បីស្តាប់ទឡ្ហីករណ៍របស់ភាគីនានា។

សាលដីការបស់អង្គបុរេជំនុំជម្រះនឹងអាចរកមើលបានតាមរយៈគេហទំព័រ៖ www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរសព្ទចល័ត៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.pheaktra@eccc.gov.kh